**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃចន្ទ័ ទី២៩ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង០៩:០០នាទីនៅក្នុងរោងចក្រ ណាហ្គាភីស ឧបភើរ សិន លីមីតធីត អាស័យដ្ឋាន ផ្លូវជាតិលេខ០១ អគារទី០១ ភូមិព្រែកត្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំង តំណាងកម្មករនិយោជិតទាំងអស់។

## ១. សមាសភាពអ្នកចូលរួម

### ក. ភាគីតំណាងអោយក្រុមហ៊ុន

-លោក Nie Chaoliang (ប្រធានរោងចក្រ)

-លោក ប៊ិល រិទ្ធី (ប្រធានផ្នែករដ្ឋបាល)

### ខ. ភាគីតំណាងសហជីពនិងតំណាងកម្មករនិយោជិត

១-អ្នកស្រី នង នីម ២-អ្នកស្រី សែម ចិន្តា ៣-អ្នកស្រី លី វណ្ណា ៤-អ្នកស្រី គុប ធីតា

៥-កញ្ញា ស៊ាងសុជាត ៦-អ្នកស្រី សុខ កុសល ៧-អ្នកស្រី ស៊ីម គុន្ធា ៨-អ្នកស្រី ស៊ុន សុខេង

៩-អ្នកស្រីប៉ាត់ ធឿន ១០-ឌឿក វ៉ាន់ ១១-អ្នកស្រី ឈី ណារី ១២-លោក អ៊ុំ អន។

## ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរការងារនៅក្នុងរោងចក្រក្នុងរយៈពេល ០១ខែដោយចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ដោយពុំសូវមានការ បញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្តល់ឲ្យភាគី នីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំង តំណាងរោងចក្រ ក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាង ក្រោម៖

១.រោងចក្របានឯកភាពផ្តល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន៣០ដុល្លាក្នុង១ខែកំឡុងពេលព្យួរ ការងារ។

Scanned with CamScanner

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ សហជីពមូលដ្ឋាន និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃការចរចានិងគោរពតាមនិតិវិធីច្បាប់។

## ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១-រោងចក្រចាប់ផ្ដើមព្យួរការងារ កម្មករនិយោជិត ចំនួន១៨៦ នាក់។ ចាប់ផ្ដើមពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ។

២. រោងចក្រផ្ដល់ប្រាក់ឈ្នួលគោល៣០ដុល្លាក្នុង១ខែក្នុងពេលព្យួរការងារ ។

៣.ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួររោងចក្រអនុញ្ញាតិអោយកម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១១:00 នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

## ក.ភាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត

១-អ្នកស្រី នង លីម ២-អ្នកស្រី សែម ចិន្តា ៣-អ្នកស្រី លី វណ្ណា ៤-អ្នកស្រី គុប ធីតា

៥-កញ្ញា សាងសុជាត ៦-អ្នកស្រី សុខ កុសល ៧-អ្នកស្រី ស៊ីម គុន្ធា ៨-អ្នកស្រី ស៊ិន សុខេង

៩-អ្នកស្រីប៉ាត់ ធឿន ១០-ឡៅ ភ៉ាន់ ១១-អ្នកស្រី ឈី ណារី ១២-លោកអ៊ុំ អន។

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

Nie Chaoliang